រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

006KH01A-01

ការអធិស្ឋានក្នុងក្រុមគ្រួសារ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៦

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ដឹកនាំអ្នក ពេលអ្នកសិក្សាមេរៀននេះ។

ការអធិស្ឋានក្នុងក្រុមគ្រួសារ

«ការអធិស្ឋានក្នុងក្រុមគ្រួសារ» ជារយៈពេលដែលសមាជិកគ្រួសារទាំងមូល ថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា ។ បើធ្វើ«ការអធិស្ឋានក្នុងក្រុមគ្រួសារ»រាល់ថ្ងៃ នៅពេលម៉ោងដដែលៗ ជាការប្រសើរបំផុត ។ ក្រុមគ្រួសារអាចអធិស្ឋាន ក្រោយពេលបាយព្រឹក ។ តាមធម្មតា ឪពុកដឹកនាំការអធិស្ឋាននេះ ប៉ុន្តែ ឪពុកត្រូវជួយគ្រួសារទាំងមូលអោយអាចចូលរួមចំណែកក្នុងការអធិស្ឋានដែរ ។ គ្រួសារទាំងមូលត្រូវអធិស្ឋាន អានព្រះគម្ពីរ ពិភាក្សាអំពីវគ្គគម្ពីរដែលកំពុងអាន និងច្រៀងសរសើរដំកើង ។ ការអធិស្ឋាននេះមិនចាំបាច់ប្រើពេលយូរទេ (ទុតិយកថា ៦:៤-៥, អេភេសូ ៥:២២-៦:៤) ។



៤- សរសេរសេចក្តីបី ឬ បួនយ៉ាង ដែលអ្នកអាចធ្វើបាន ក្នុងពេលអធិស្ឋានជាមួយក្រុមគ្រួសារ ។

កិច្ចការដែលត្រូវអនុវត្ត

- ទន្ទេញ កំណើតពិភពលោក ១៨:១៩ ។
- អធិស្ឋានក្នុងក្រុមគ្រួសារជារៀងរាល់ថ្ងៃ ។
- បង្រៀនមេគ្រួសារនៅក្នុងក្រុមជំនុំរបស់អ្នក អោយធ្វើដូចនេះដែរ ។

© Project WorldReach © SEAN

យោបល់ផ្សេងទៀត : អានសៀវភៅដំណឹងល្អណាមួយ មួយថ្ងៃ បន្តិចៗ រាល់ថ្ងៃ តាំងពីដើមរហូតដល់ចប់ ។ រួចអាន «ទំនុកតម្កើង » «សុភាសិត » និង «កិច្ចការពួកសាវក » ដូចគ្នានេះដែរ ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើអ្នកណាទទួលខុសត្រូវលើការអធិស្ឋានក្នុងក្រុមគ្រួសារ ?

_____

_____

២- តើយើងបង្រៀនកូនៗយើងអោយចេះអធិស្ឋាន ដោយរបៀបណា ?

_____

_____

៣- ហេតុអ្វីបានជាការអធិស្ឋានក្នុងក្រុមគ្រួសារ ជាការសំខាន់ ?

_____

_____

តើក្រុមគ្រួសារអ្នកធ្វើ «ការអធិស្ឋានក្នុងក្រុមគ្រួសារ» ដែរឬទេ ?

☐ ធ្វើ ។

☐ មិនធ្វើទេ ប៉ុន្តែ យើងនឹងចាប់ផ្តើមធ្វើពេលនេះ ។

ការអធិស្ឋានក្នុងក្រុមគ្រួសារ មិនអាចជំនួសការអធិស្ឋានផ្ទាល់ខ្លួនទេ ។ កូនរបស់ព្រះជាម្ចាស់ម្នាក់ៗ ត្រូវអធិស្ឋានផ្ទាល់ខ្លួនទៅព្រះបិតារបស់ខ្លួន ដែលគង់នៅស្ថានបរមសុខ ។

តើអ្នកមានយកពេលអធិស្ឋាន និងអានព្រះបន្ទូលរបស់ព្រះជាម្ចាស់ អោយបានរាល់ថ្ងៃដែរឬទេ ?

☐ មាន

☐ ខ្ញុំមិនបានធ្វើទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

មួយវិញទៀត ការអធិស្ឋានក្នុងក្រុមគ្រួសារ មិនអាចជំនួសការប្រជុំជាមួយក្រុមជំនុំទេ ។



ពេលសំរាប់អធិស្ឋានមានបួន

- យើងអធិស្ឋានផ្ទាល់ខ្លួន តែម្នាក់ឯង ។



- ☐ ព្រះយេស៊ូសំអាតព្រះវិហារ (ម៉ាថាយ ២១:១២-១៦)
- ☐ ព្រះយេស៊ូមានព្រះជន្មរស់ឡើង... វិញ (ម៉ាថាយ ២៨:១-១០)
- ☐ មហាបណ្តាំ... (បេសកកម្មសកលលោក) (ម៉ាថាយ ២៨:១៨-២០)
- ☐ បុរសខ្វាក់ភ្នែក (យ៉ូហាន ៩:១-៤១)
- ☐ អ្នកស្រុកសាម៉ារីដែលមានចិត្ត សប្បុរស (លូកា ១០:២៥-៣៧)
- ☐ កូនពៅដែលវង្វេង (លូកា ១៥:១១-៣២)
- ☐ បុរសអ្នកមាន និងឡាសារជា... អ្នកក្រ (លូកា ១៦:១៩-៣១)
- ☐ ព្រះយេស៊ូប្រទានចំណីអាហារ... ដល់មនុស្សប្រាំពាន់នាក់ (យ៉ូហាន ៦:១-១៥)
- ☐ លោកសូលថ្វាយខ្លួន (កិច្ចការ ៩:១-១៩)

© Project WorldReach © SEAN

☐ ព្រះមហាក្សត្រិយានីនៃស្រុកសាបា (២ របាក្សត្រ ៩:១-១២)

☐ ស្តេចយ៉ូស្យាស (២ របាក្សត្រ ៣៤)

☐ លោកអែសរ៉ាអានគម្ពីរវិន័យ (នេហេមី ៨:១-១២)

☐ ព្រះជាម្ចាស់ជាអ្នកគង្វាលរបស់ខ្ញុំ (ទំនុកតម្កើង ២៣)

☐ ចំរៀងសរសើរដំកើង (ទំនុកដំកើង ១៥០)

☐ ឡភ្លើងសន្ធោសន្ធៅ (ដានីអែល ៣)

☐ លោកដានីអែល និងសត្វតោ (ដានីអែល ៦)

☐ កំណើតរបស់ព្រះយេស៊ូ (លូកា ២:១-២០)

☐ ពួកហោរាចារ្យមក...
ថ្វាយបង្គំព្រះយេស៊ូ (ម៉ាថាយ ២:១-១២)

☐ ព្រះយេស៊ូទទួលពិធីជ្រមុជទឹក (ម៉ាថាយ ៤:១-១១)

☐ ព្រះយេស៊ូត្រូវល្បួង (ម៉ាកុស ១:១-១១)

☐ ព្រះយេស៊ូយាងដើរលើទឹក (ម៉ាថាយ ១៤:២២-៣៣)

- ក្រុមគ្រួសារទាំងមូលអធិស្ឋានជាមួយគ្នា ។



- អ្នកជឿអធិស្ឋានជាមួយគ្នានៅក្នុងការថ្វាយបង្គំ ។



- យើងអធិស្ឋានទាក់ទងជាប់ជាមួយព្រះជាម្ចាស់..... (១ ថែស្សាឡូនិក ៥:១៧) ។ ឧទាហរណ៍ : យើងអរព្រះគុណព្រះជាម្ចាស់មុនពេលទទួលទានអាហារ ឬ នៅពេលដែលយើងបានទទួលអ្វីមួយ ។

© Project WorldReach © SEAN



- កូនត្រូវអរព្រះគុណព្រះជាម្ចាស់ ចំពោះកិច្ចការទាំងអស់ ដែលព្រះអង្គបានធ្វើ ។
- សរសើរដំកើងព្រះអង្គ ដោយប្រើបទគម្ពីរទំនុកតម្កើង និង ចំរៀងថ្វាយបង្គំ ។
- ទូលសូមឱ្យព្រះជាម្ចាស់អត់ទោសបាបឱ្យកូន ។ កូនត្រូវទុកចិត្តថា ព្រះអង្គលើកលែងទោសអំពើបាបរបស់កូន ទោះជាអំពើបាប ដែលកូនបានប្រព្រឹត្តក្នុងថៃនេះក៏ដោយ ។ បើកូនទុកចិត្តថា ព្រះអង្គលើកលែងទោសឱ្យកូន នោះកូននឹងមានសេរីភាព គឺថាកូននឹងមានអារម្មណ៍ថា ព្រះអង្គស្រឡាញ់កូន និង គាប់ព្រះហឫទ័យនឹងកូន ហើយកូនអាចនឹងទូលសូមអោយព្រះអង្គជួយកូនអោយអាចកែប្រែបាន ដោយសេរី ។ កូនត្រូវទូលសូមអោយព្រះជាម្ចាស់បំពេញកូន ដោយទ្វានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធជានិច្ច ។
- កូនត្រូវអធិស្ឋានឱ្យមិត្តភក្តិកូន ។ អធិស្ឋានឱ្យប្រទេសជាតិកូន និងឱ្យអ្នកគ្រប់គ្រងរបស់យើង ។ (១ ធម ២:១-២)
- កូនត្រូវអធិស្ឋានទូលសូមឱ្យបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីអោយកូនអាចរស់ដើម្បីព្រះយេស៊ូ ។
- អធិស្ឋានអោយក្រុមជំនុំ និង គ្រួគង្វាលរបស់កូន ។

☐	លោកណូអេ	(កណ. ៦:៥-២២)
☐	លោកអាប្រាហាំ និងអ៊ីសាក់	(កណ. ២២:១-១៨)
☐	សុបិនរបស់លោកយ៉ាកុប	(កណ. ២៨:១០-២២)
☐	ព្រះជាម្ចាស់ត្រាស់ហៅ... លោកម៉ូសេ	(សេរីភាព ៣:១-១៥)
☐	ការឆ្លងកាត់សមុទ្រក្រហម	(សេរីភាព ១៤)
☐	បទបញ្ជាទាំងដប់	(សេរីភាព ២០:១-២២)
☐	លោកយ៉ូស៊ូអាវាយយកបាន ក្រុងយេរីខូ	(យ៉ូស៊ូអា ៦)
☐	ដាវីឌ និង កូលីយ៉ាត	(១ សាមូអែល ១៧)
☐	លោកអេលីយ៉ា និងពួក ព្យាការីព្រះបាល	(១ ពង្ស. ១៨:២០-៤០)
☐	លោកអេលីសេ... និងលោកណាម៉ាន់	(២ ពង្ស. ៥:១-១៤)

© Project WorldReach © SEAN

- អានវគ្គគម្ពីរដែលអ្នកបានជ្រើសយក ។ ម្នាក់ៗអាចអាន ខ គម្ពីរមួយ រួមទាំងកូនៗដែរ ។
- ពិភាក្សាអំពីវគ្គគម្ពីរដែលបានអាន ។ អ្នកអាចសួរថា៖ «តើអ្នកពេញចិត្ត ខ គម្ពីរណាជាងគេ ? » ឬ «តើត្រង់នេះព្រះជាម្ចាស់បង្រៀនយើងអំពីអ្វី ? » ។ ក្រុមគ្រួសារទាំងមូលត្រូវចូលរួមពិភាក្សាគ្នា ។ អ្នកមិនមែនត្រូវ«អធិប្បាយ»ទេ ។
- ត្រូវអធិស្ឋានទាំងអស់គ្នា ។
- ត្រូវច្រៀងសរសើរដំកើង ។

កូនៗមិនអាចយល់ព្រះគម្ពីរទាំងអស់ទេ ។ ខគម្ពីរជាបន្តបន្ទាប់នេះ កូនៗអាចអានហើយយល់បាន ។ សូមគូសសញ្ញា «✓»នេះ ក្នុងប្រអប់ « □ »នេះ នៅពេលដែលកូនៗបានអានរួចហើយ ។

ខ គម្ពីរសំរាប់អានជាមួយនឹងកូនៗ

□ ការបង្កើត (កំណើតពិភពលោក ១)

□ លោកអាដាម និងនាងអេវ៉ា (កំណើតពិភពលោក ៣)

ក្នុងចំណោមយោបល់ខាងលើនេះរបស់ឪពុកអំពីការអធិស្ឋាន តើយោបល់ណាខ្លះ ដែលអ្នកត្រូវអធិស្ឋានកាន់តែខ្លាំង នៅពេលធ្វើការអធិស្ឋានក្នុងក្រុមគ្រួសារ ? សូមសរសេរអំពីផែនការរបស់អ្នក:

© Project WorldReach © SEAN

ការចូលរួមចំណែករបស់កូនៗ ក្នុងការអធិស្ឋានក្នុងក្រុមគ្រួសារ

កូនៗត្រូវចូលរួមអធិស្ឋានដែរ ។ ការធ្វើដូចនេះ ពង្រឹងជំនឿរបស់កូនៗ ដើម្បីអោយកូនៗនោះអាចដើរតាមព្រះអម្ចាស់យេស៊ូ ជារៀងរាល់ថ្ងៃពេញមួយជីវិត ។ បើសិនជាយើងមិនយកចិត្តទុកដាក់អធិស្ឋានទេ កូនៗរបស់យើងនឹងធ្វើតាមគំរូមិនល្អរបស់យើង ។ អេភេសូ ៦:៤ ចែងថា÷ *«រីឯបងប្អូនដែលជាឪពុកវិញ កុំធ្វើឱ្យកូនរបស់ខ្លួនមួម៉ៅនោះឡើយ តែត្រូវអប់រំវា ដោយពាក្យប្រៀនប្រដៅ និងជំបួន្មាន ស្របតាមព្រះអម្ចាស់»* ។

តើអ្នកណាដែលទទួលខុសត្រូវ ធ្វើអោយកូនៗរីកចំរើនឡើង ជាគ្រីស្តជន ?

☐ សាលារៀន ។

☐ គ្រូគង្វាល ឬ ក្រុមជំនុំ ។

☐ ឪពុកម្តាយ ។

ឪពុកម្តាយត្រូវដឹកនាំការអធិស្ឋានក្នុងក្រុមគ្រួសារ ឯកូនៗត្រូវចូលរួមចំណែកដែរ ។ យើងបង្រៀនកូនៗអោយចេះអធិស្ឋានតាមគំរូរបស់យើងផ្ទាល់ និងលើកទឹកចិត្តកូនៗអោយអធិស្ឋានសំរាប់អ្វីៗ ដែលទាក់ទងនឹងកូនៗផ្ទាល់ (មិត្តភក្តិពួកគេ អ្វីៗដែលទាក់ទងនឹងសាលារៀន ។ល។) ។ កូនៗមិនត្រូវគិតថា ការអធិស្ឋានក្នុងក្រុមគ្រួសារជាបន្ទុកមួយទេ តែត្រូវគិតថា ជាការជួបជុំគ្នាដែលសប្បាយរីករាយវិញ ។

តើអ្នកបានបង្រៀនកូនៗអោយចេះអធិស្ឋានដែរឬទេ ?

តើអ្នកអធិស្ឋានជាមួយកូនៗដែរឬទេ ?

របៀបអធិស្ឋានក្នុងក្រុមគ្រួសារ

យើងនឹងរៀបរាប់អំពីរបៀបអធិស្ឋានក្នុងក្រុមគ្រួសារមួយ ។

- ទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធ ជួយអ្នកអោយអាចយល់ព្រះគម្ពីរគ្រប់គ្នា ។